ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន

លេខ: 006 សរណន សក

# សារាចរណែនាំ

# ស្តីពី

# ការគ្រប់គ្រងវិស័យនាវាចរណ៍សមុទ្រ

យោងអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការកែលំអ និង បំពេញបន្ថែម អនុក្រឹត្យស្តីពីការប្រមូលពន្ធតែមសារពើពន្ធ ប្រកាសលេខ ១៨៩ ប្រក.សក ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់នាយកដ្ឋាននាវាជំនួញសមុទ្រ ប្រកាសលេខ ៨៥២ ប្រក.សក.សហវ ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៥ ស្តីពីការកំណត់ថ្លៃលើប័ណ្ណសំគាល់ផ្លាកលេខ-ប័ណ្ណបើកបរ-ច្បាប់អនុញ្ញាតិធ្វើអាជីវកម្ម ត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត-ជលយាន-ជលយានយន្ត និង សាឡង់គ្រប់ប្រភេទ ដើម្បីគ្រប់គ្រងវិស័យនាវាចរណ៍សមុទ្រឱ្យមានប្រសិទ្ធភាព ធានាបាននូវសណ្តាប់ធ្នាប់ និង សុវត្ថិភាពនាវាចរតាមផ្លូវសមុទ្រ រួមទាំងអាយុជីវិតប្រជាពលរដ្ឋ ជាពិសេសអ្នកប្រើប្រាស់នាវាសមុទ្រ និង រួមចំណែកការពារបរិស្ថានសមុទ្រឱ្យបានល្អ ។

ក្រសួងសាធារណការ និង ដឹកជញ្ជូន សូមធ្វើសេចក្តីណែនាំ ដូចតទៅ :

## ជំពូក I

## ប័ណ្ណសំគាល់នាវា

### I- ការផ្តល់ប័ណ្ណសំគាល់នាវា

នាវាគ្រប់ប្រភេទ លើកលែងតែនាវារបស់កងយុទ្ធពលខេមរភូមិន្ទ និងអង្គភាពនគរបាល ដែលធ្វើនាវាចរតាមផ្លូវសមុទ្រ រួមមាន នាវាចរណ៍ផ្នែកទេសាទ នាវាចរណ៍ផ្នែកចរាចរ នាវាចរណ៍ផ្នែកកំសាន្ត និងនាវាចរណ៍ផ្នែកស្រាវជ្រាវ និងរុករក មានទម្ងន់ផ្ទុកចាប់ពី ១តោន ឡើង ឬអ៊ីប័រគ្រប់ប្រភេទ ជាកម្មសិទ្ធិរបស់រដ្ឋ ឯកជន ឯកជនចំរុះរដ្ឋ ឬជនបរទេស ដែលស្នាក់នៅជាបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានប័ណ្ណសំគាល់នាវា ដែលចេញដោយ

**១-ក្រសួងសាធារណការ និង ដឹកជញ្ជូន (នាយកដ្ឋាននាវាចរណ៍ទូទៅ)**

ក-នាវាគ្រប់ប្រភេទដែលមានទំងន់ផ្ទុកលើសពី ២០ តោន ឬដឹកអ្នកដំណើរលើសពី ៣០ កន្លែង ។

ខ-នាវាគ្រប់ប្រភេទដែលធ្វើនាវាចរពីខេត្ត-ក្រុងមួយ ទៅខេត្ត-ក្រុងមួយទៀត ។

គ-នាវានេសាទដែលមានអនុភាពម៉ាស៊ីនលើសពី ៧៥ សេះ ។

ឃ-នាវាគ្រប់ប្រភេទដែលធ្វើនាវាចរឆ្លងដែនពីប្រទេសកម្ពុជា ទៅប្រទេសផ្សេងទៀត ឬត្រឡប់មកវិញដោយមិនគិតពីទម្ងន់ផ្ទុក ឬអនុភាពម៉ាស៊ីន ឬចំនួនកន្លែងអ្នកដំណើរឡើយ ។

ង-នាវាគ្រប់ប្រភេទរបស់ជនបរទេសដែលស្នាក់នៅជាបណ្ដោះអាសន្ន ឬអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ច-អូប៊័រគ្រប់ប្រភេទ ដោយមិនគិតពីអនុភាពម៉ាស៊ីន ។

**២-មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង**

ក-នាវាគ្រប់ប្រភេទដែលមានទម្ងន់ផ្ទុកពី ២០ តោនចុះ ឬ ដឹកអ្នកដំណើរចាប់ពី ១២ កន្លែង ដល់ ៣០ កន្លែង ។

ខ-នាវានេសាទដែលមានអនុភាពម៉ាស៊ីនចាប់ពី ៧៥ សេះចុះ ។

**៣-**ការត្រួតពិនិត្យជាប្រចាំនៅលើនាវាគ្រប់ប្រភេទដែលស្ថិតនៅក្នុងខេត្ត-ក្រុងនីមួយៗ ត្រូវប្រគល់អោយមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុងនោះ ជំនួសមុខអោយក្រសួងសាធារណការ និងដឹកជញ្ជូន លើកលែងតែក្នុងករណីចាំបាច់ ។

## II- ការដាក់ពាក្យសុំប័ណ្ណសំគាល់នាវា

ម្ចាស់នាវា ត្រូវដាក់ពាក្យសុំប័ណ្ណសំគាល់នាវាតាមទីកន្លែង និងពេលវេលាដូចខាងក្រោម :

**១-នៅនាយកដ្ឋាននាវាចរណ៍ទូទៅ**

ក-ក្នុងរយៈពេល ១ ខែ ចំពោះនាវាដែលទិញ ឬសាងសង់ហើយនៅក្រុងព្រះសីហនុ ខេត្តកំពត ក្រុងកែប និងខេត្តកោះកុង ដោយគិតចាប់ពីថ្ងៃធ្វើលិខិតលក់ ឬលិខិតសាងសង់រួច ។

ខ-ក្នុងរយៈពេល ២ ខែ ចំពោះនាវាដែលទិញ ឬសាងសង់ហើយ នៅបណ្ដាខេត្ត-ក្រុងដទៃទៀតដោយគិតចាប់ពីថ្ងៃធ្វើលិខិតលក់ ឬលិខិតសាងសង់រួច ។

គ-ក្នុងរយៈពេល ៣ ខែ ចំពោះនាវាដែលនាំចូលពីបរទេសដោយគិតចាប់ពីថ្ងៃដែលបានបង់ពន្ធរួច ។

**២-នៅមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង**

ក-ក្នុងរយៈពេល ១ ខែ ចំពោះនាវាដែលទិញ ឬសាងសង់ហើយនៅក្នុងខេត្ត-ក្រុងរបស់ខ្លួនដោយគិតចាប់តាំងពីថ្ងៃធ្វើលិខិតលក់ ឬលិខិតសាងសង់រួច ។

ខ-ក្នុងរយៈពេល ២ ខែ ចំពោះនាវាដែលទិញ ឬសាងសង់ហើយនៅបណ្ដាខេត្ត-ក្រុងដទៃទៀតដោយគិតចាប់ពីថ្ងៃធ្វើលិខិតលក់ ឬលិខិតសាងសង់រួច ។

គ-ក្នុងរយៈពេល ៣ ខែ ចំពោះនាវាដែលនាំចូលពីបរទេសដោយគិតចាប់ពីថ្ងៃដែលបានបង់ពន្ធរួច ។

## III. សំណុំលិខិតសុំបណ្ណសំគាល់នាវា

ការដាក់ពាក្យសុំប័ណ្ណសំគាល់នាវា ត្រូវអនុវត្តតាមសំណុំលិខិតដូចខាងក្រោម :

១-ពាក្យសុំប័ណ្ណសំគាល់នាវា ០១ច្បាប់ ដែលមានបិទតែមត្រឹមត្រូវ ។

២-លិខិតលក់ ឬលិខិតសាងសង់ ០១ច្បាប់ ។ នៅក្នុងលិខិតលក់ត្រូវមានបញ្ជាក់ច្បាស់លាស់អំពីអាស័យដ្ឋានអ្នកលក់ និង អ្នកទិញ មានសាក្សីដឹងឮ និង មានការបញ្ជាក់ពីអាជ្ញាធរដែនដីដោយមានប្រថាប់ត្រាផង ។ ចំពោះនាវាសាងសង់ថ្មី "ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០០" ត្រូវមានលិខិតសាងសង់ដែលមានហត្ថលេខាទទួលស្គាល់ពីប្រធានសំណង់ ឬ ប្រធានការដ្ឋានសាងសង់នាវា ០១ច្បាប់ ។

៣-លិខិតបញ្ជាក់ទីលំនៅរបស់អ្នកសុំប័ណ្ណសំគាល់នាវា ០១សន្លឹក និង ប័ណ្ណគ្រួសារ ឬអត្តសញ្ញាណប័ណ្ណ ឬ លិខិតសំគាល់ខ្លួន ។

៤-ប្រសិនបើនាវាជាកម្មសិទ្ធិរបស់រដ្ឋ ឬអង្គភាពរដ្ឋ ត្រូវមានលិខិតបញ្ជាក់ពីប្រធានអង្គភាពនោះ ។

៥-ប្លង់សាងសង់ និងលិខិតប្រវត្តិនាវា ០១ច្បាប់ ។

៦-បង្កាន់ដៃពន្ធ ០១សន្លឹក ។

## IV. ការកំណត់ផ្លាកលេខនាវា

### ១. ចង្កោមលេខ

ផ្លាកលេខរបស់នាវាសមុទ្រគ្រប់ប្រភេទដែលធ្វើនាវាចរតាមផ្លូវសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបែងចែកតាមចង្កោមលេខដូចខាងក្រោម :

| | | |
|---|---|---|
| ចង្កោមលេខ | ១-នាវាដឹកអ្នកដំណើរ | ៧-នាវាស្រាវជ្រាវ និងរុករក |
| | ២-នាវាដឹកទំនិញ | ៨-នាវារបស់អង្គភាពរដ្ឋ |
| | ៣-នាវាដឹកប្រេងឥន្ធនៈ | ៩- នាវារបស់ឯកជនធំៗរះរដ្ឋ |
| | ៤-នាវាសណ្តោង | ១០- នាវារបស់ជនបរទេស |
| | ៥-នាវាទេសចរណ៍ | ១១- នាវាសង្គ្រោះ ។ |
| | ៦-នាវានេសាទ | |

### ២. អក្សរដើម

អក្សរដើមនៅលើផ្លាកលេខនាវាសមុទ្រគ្រប់ប្រភេទ ដែលធ្វើនាវាចរតាមផ្លូវសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលត្រូវសុំធ្វើផ្លាកលេខនៅនាយកដ្ឋាននាវាជំនួញសមុទ្រ នៃក្រសួងសាធារណការ និង ដឹកជញ្ជូន ត្រូវកំណត់យក ភព ។ ចំពោះផ្លាកលេខ ដែលសុំនៅមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង អក្សរដើមត្រូវកំណត់យកតួអក្សរ ដូចមានចែងនៅក្នុងចំណុច IV-3 ខាងក្រោម ។ ក្នុងករណីនេះ ផ្លាកលេខមិនត្រូវមានតួអក្សរចុងទេ ។

### ៣-អក្សរចុង

អក្សរចុងនៅលើផ្លាកលេខសំគាល់នាវាគ្រប់ប្រភេទ ដែលធ្វើនាវាចរតាមផ្លូវសមុទ្រ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានកំណត់ដូចខាងក្រោម :

| | | | |
|---|---|---|---|
| ក-ក្រុងព្រះសីហនុ | ក្រស | គ-ក្រុងកែប | ក្រក |
| ខ-ខេត្តកំពត | កព | ឃ-ខេត្តកោះកុង | កក |

### ៤-ពណ៌ ទំហំអក្សរ និងលេខ

អក្សរ និង លេខរបស់នាវាសមុទ្រគ្រប់ប្រភេទដែលធ្វើនាវាចរតាមផ្លូវសមុទ្រ នៃព្រះរាជាណាចក្រកម្ពុជាត្រូវមានពណ៌ខ្មៅ ។

ទំហំអក្សរ និងលេខ ត្រូវកំណត់ដូចខាងក្រោម ដោយមិនគិតអំពីមាឌរបស់នាវាឡើយ ។

| | | | |
|---|---|---|---|
| -កំពស់ | ២៤ សម | - កំរាស់ | ៤ សម |
| -ទទឹង | ១២ សម | - ចន្លោះ | ៣.៥សម ។ |

### ៥-ទីតាំងផ្លាកលេខ

ផ្លាកលេខរបស់នាវាសមុទ្រគ្រប់ប្រភេទ ដែលធ្វើនាវាចរតាមផ្លូវសមុទ្រ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់នៅសងខាង ផ្នែកខាងក្រោមនៃជញ្ជាំងមុខរបស់នាវា (ស្ថិតនៅចំពាក់កណ្ដាលគ្រែង) ។ ផ្លាកលេខត្រូវបាញ់ថ្នាំ ឬ លាបថ្នាំភ្ជាប់នឹងជញ្ជាំងនាវាតែម្តង ។

### ៦-លេខរៀង

នៅចន្លោះអក្សរដើម-ចង្អាមលេខ និងអក្សរចុងនៃផ្លាកលេខនីមួយៗ ត្រូវមានលេខរៀងដែលមានចំនួន ៤លេខ ។

### ៧-រូបភាពផ្លាកលេខ

ផ្លាកលេខនាវាសមុទ្រគ្រប់ប្រភេទត្រូវមានអក្សរ និង លេខពណ៌ខ្មៅសរសេរភ្ជាប់នឹងជញ្ជាំង ឬផ្លាកលើជញ្ជាំងពណ៌ស ។

ឧទាហរណ៍ : ភព១-០០០១ កក កក១-០០០១

ចំពោះនាវាដែលធ្វើអាជីវកម្មឆ្លងកាត់ព្រំដែនប្រទេសជាប្រក្រតី លេខសំគាល់ត្រូវមានរូបភាពដូចខាងក្រោម :

១-ចំនួន ២លេខចុងក្រោយ នៃឆ្នាំដែលនាវានោះបានចុះបញ្ជី

២-ចំនួន ២លេខចុងក្រោយ នៃឆ្នាំដែលនាវានោះត្រូវបានសាងសង់

៣-លេខរៀងចំនួន ៣លេខ ។

ឧទាហរណ៍ នៃលេខសំគាល់ផ្លូវការ : ៩៩៨៤០០១ ។

ចំពោះលក្ខណៈផ្សេងៗរបស់នាវាដែលត្រូវធ្វើនាវាចរឆ្លងដែន ដូចជាទង់ជាតិ ឈ្មោះនាវា និង ឈ្មោះកំពង់ផែចុះបញ្ជីព្រមទាំងទីតាំងនៃទង់ជាតិ ឈ្មោះនាវា និង ឈ្មោះកំពង់ផែចុះបញ្ជីជាដើម ត្រូវអនុវត្តតាមច្បាប់អន្តរជាតិ ។

**៨-ផ្លាកទិសដៅ**

នាវាដឹកជញ្ជូនអ្នកដំណើរ ដឹកទំនិញ និង នាវាសណ្តោង ត្រូវមានផ្លាកទិសដៅដាក់នៅសងខាងនាវា ផ្នែកខាងមុខទទឹមនឹងអ្នកបើកបរ ។

នៅក្នុងផ្លាកទិសដៅ ត្រូវសរសេរបង្ហាញអំពី :

-ប្រភេទនាវា " ដឹកអ្នកដំណើរ ដឹកទំនិញ ឬសណ្តោង "

-ទិសដៅ " ស្រែអំបិល-កោះកុង "

-ទម្ងន់ផ្ទុកទំនិញ ឬ ចំនួនកន្លែងអ្នកដំណើរ

-ទម្ងន់សរុប ។

ផ្លាកទិសដៅត្រូវមានទំហំស្របទៅតាមប្រភេទ ឬទំហំនាវាដូចខាងក្រោម :

ក-នាវាដែលមានបណ្តោយ ៣០មឡើងទៅ ផ្លាកទិសដៅត្រូវមានទំហំទទឹង ១.១០ម និង បណ្តោយ ២.២០ម ។

ខ- នាវាដែលមានបណ្តោយ ១៨ម ដល់ ២៩ម ផ្លាកទិសដៅត្រូវមានទំហំទទឹង ០.៧០ម និង បណ្តោយ ១.២០ម ។

គ-ចំពោះនាវារបស់ឯកជន ឬ ឯកជនចំរុះរដ្ឋ ធ្វើអាជីវកម្មដឹកជញ្ជូនជាសាធារណៈ ផ្លាកទិសដៅត្រូវលាបពណ៌ស អក្សរ និងលេខ ត្រូវលាបពណ៌ខ្មៅ ។

ឃ-ចំពោះនាវារបស់ឯកជនដឹកជញ្ជូនទំនិញផ្ទាល់ខ្លួន ផ្លាកទិសដៅត្រូវលាបពណ៌ខ្មៅ អក្សរ និង លេខ ត្រូវប្រើពណ៌ស ។

ង-ចំពោះនាវារបស់រដ្ឋ ផ្លាកទិសដៅត្រូវលាបពណ៌ក្រហម អក្សរ និងលេខត្រូវលាបពណ៌ស ។

**៩-ឈ្មោះនាវា**

ក-ឈ្មោះនាវា ត្រូវអាស្រ័យដោយម្ចាស់នាវាជាអ្នកដាក់ឱ្យ និង ត្រូវមានការឯកភាពពីស្ថាប័នប្រគល់ប័ណ្ណសំគាល់នាវា ។

ខ-នៅក្នុងតំបន់អាជីវកម្មតែមួយ ឈ្មោះនាវាមិនត្រូវដូចគ្នាឡើយ លើកលែងតែនាវាជាកម្មសិទ្ធិរបស់ម្ចាស់តែមួយ ។ ក្នុងករណីនេះ ត្រូវចុះលេខរៀងនៅពីក្រោយឈ្មោះនាវានោះ ។ ឧទាហរណ៍: Royal 7 ។

គ-ឈ្មោះនាវាត្រូវសរសេរពណ៌ខ្មៅ ស្ថិតពីលើ និងចំពាក់កណ្តាលផ្លាកលេខ ។

# ជំពូក II

# ការសាងសង់ និង ជួសជុលនាវា

## I- ការសាងសង់

១-ការសាងសង់ ឬការបង្កើតការដ្ឋានសាងសង់នាវាសមុទ្រគ្រប់ប្រភេទដូចមានចែងក្នុងជំពូក I អាចប្រព្រឹត្តទៅបានលុះត្រាតែមានលិខិតអនុញ្ញាត ។

២-ការបង្កើតការដ្ឋានសាងសង់នាវាសមុទ្រគ្រប់ប្រភេទ ត្រូវចេញដោយក្រសួងសាធារណការ និង ដឹកជញ្ជូន (នាយកដ្ឋាននាវាជំនួញសមុទ្រ) ។

៣-និតិបុគ្គល ឬរូបវន្តបុគ្គល ដែលមានបំណង ឬបង្កើតការដ្ឋានសាងសង់ ឬជួសជុលនាវា ត្រូវដាក់ពាក្យសុំតាមរយៈមន្ទីរសាធារណការ និង ដឹកជញ្ជូន មកនាយកដ្ឋាននាវាជំនួញសមុទ្រ ដោយមានសំណុំលិខិតដូចខាងក្រោម :

ក-ពាក្យសុំ ០១ច្បាប់ ដែលមានបិទតែមត្រឹមត្រូវ ។

ខ-ទីតាំងនៃការដ្ឋានសាងសង់ ឬជួសជុលនាវា ដែលមានប្លង់ដីកម្មសិទ្ធផ្ទាល់ ឬជួលដោយមានបញ្ជាក់ទទួលស្គាល់ពីអាជ្ញាធរដែនដី ។ ក្នុងករណីជួលការដ្ឋានសាងសង់ ឬជួសជុលនាវា ត្រូវមានកិច្ចសន្យាជួល ។

គ-លិខិតវាយតំលៃហេតុប៉ះពាល់បរិស្ថាន EIA ឬលិខិតវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង IEI ។

ឃ-លិខិតបញ្ជាក់ទីលំនៅ និងប័ណ្ណគ្រួសារ ឬអត្តសញ្ញាណប័ណ្ណ ឬលិខិតសំគាល់ខ្លួន ។

ង-ប្លង់ការដ្ឋាន ដែលមានបញ្ជាក់ទទួលស្គាល់ពីមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង ។

អ៦ ច-បង្កាន់ដៃពន្ធដារ ។

៤-ម្ចាស់ការដ្ឋានសាងសង់នាវាសមុទ្រ ត្រូវដាក់ពាក្យសុំសាងសង់នាវានៅតាមស្ថាប័នដូចមានចែងនៅក្នុងជំពូក I ត្រង់ចំណុច I,១ និង I,២ តាមសំណុំលិខិតដូចខាងក្រោម :

ក-ពាក្យសុំ ០១ច្បាប់ ដែលមានបិទតែមត្រឹមត្រូវ

ខ-គំរោងប្រើប្រាស់សំភារៈ ០១ច្បាប់

គ-ប្លង់នាវា ០១ច្បាប់

ឃ-លិខិតបញ្ជាក់ទីលំនៅ ០១ច្បាប់ និងប័ណ្ណគ្រួសារ ឬអត្តសញ្ញាណប័ណ្ណ ឬលិខិតសំគាល់ខ្លួន

ង-ឈ្មោះ និងទីកន្លែងសាងសង់ ។

៥-នៅពេលទទួលលិខិតអនុញ្ញាតឱ្យសាងសង់ហើយ នាយកដ្ឋាននាវាជំនួញសមុទ្រ ឬ មន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត-ក្រុង ត្រូវប្រគល់សៀវភៅប្រវត្តិនាវាទៅម្ចាស់សាងសង់ ។ សៀវភៅនេះមួយក្បាល គឺសំរាប់តែនាវាមួយគ្រឿងប៉ុណ្ណោះ ។ នៅពេលសាងសង់រួចហើយ ត្រូវមានហត្ថលេខាទទួលស្គាល់ពីម្ចាស់សំណង់ ឬ ប្រធានការដ្ឋានសាងសង់នៅលើសៀវភៅប្រវត្តិនាវានោះ ។

## II- ការជួសជុល

១-ការជួសជុលនាវាសមុទ្រគ្រប់ប្រភេទត្រូវមានលិខិតអនុញ្ញាត ដែលចេញដោយស្ថាប័នដូចមានចែងក្នុងជំពូក I ត្រង់ចំណុច I,១ និង I,២ ខាងលើ ។

២-ម្ចាស់នាវា ឬម្ចាស់ការដ្ឋានសាងសង់ ឬជួសជុលនាវាត្រូវដាក់ពាក្យសុំមកស្ថាប័នដូចមានចែងក្នុង ជំពូក I ត្រង់ចំណុច I,១ និង I,២ តាមសំណុំលិខិតដូចខាងក្រោម :

ក-ពាក្យសុំ ០១ច្បាប់ដែលមានបិទតែមត្រឹមត្រូវ

ខ-គំរោងសំភារៈជួសជុល ០១ច្បាប់

គ-សៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេស និងសៀវភៅប្រវត្តិនាវា

ឃ-លិខិតបញ្ជាក់ទីលំនៅ ០១ច្បាប់ និងប័ណ្ណគ្រួសារ ឬអត្តសញ្ញាណប័ណ្ណ ឬលិខិតសំគាល់ខ្លួន ។

ង-ឈ្មោះ ឬទីកន្លែងជួសជុលនាវា ។

៣-ការជួសជុលនាវាស្របតាមសំណើរបស់សមត្ថកិច្ចត្រួតពិនិត្យលក្ខណៈបច្ចេកទេស ឬសមត្ថកិច្ចត្រួតពិនិត្យផ្នែក អាចប្រព្រឹត្តទៅបានដោយពុំមានការដាក់ពាក្យសុំដូចមានចែងនៅក្នុងចំណុច II,២ ខាងលើនេះឡើយ ។

៤-នៅពេលជួសជុលហើយ ម្ចាស់ការដ្ឋានជួសជុលនាវាត្រូវចេញលិខិតជួសជុលឱ្យម្ចាស់នាវា ។ ក្នុងករណីនេះ នាវាត្រូវដាក់ឱ្យធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសឡើងវិញ មុនពេលចេញលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម ។

## III. ការប្តូរម៉ាស៊ីននាវា

ការប្តូរម៉ាស៊ីននាវាសមុទ្រគ្រប់ប្រភេទ ត្រូវមានលិខិតអនុញ្ញាតពីស្ថាប័នផ្តល់ប័ណ្ណសំគាល់នាវា ។ ម្ចាស់នាវាត្រូវដាក់ពាក្យសុំប្តូរប័ណ្ណសំគាល់នាវាថ្មី ដែលមានបិទតែមត្រឹមត្រូវ ។ ក្នុងករណីនេះ ផ្លាកលេខត្រូវរក្សាទុកដដែល ដោយគ្រាន់តែធ្វើការកែតម្រូវក្នុងបញ្ជីគ្រប់គ្រងនាវាតែប៉ុណ្ណោះ ។

# ជំពូក III

# លក្ខណៈបច្ចេកទេសនាវា

## I. សៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេស

មុនធ្វើអាជីវកម្ម ឬទទួលលិខិតអនុញ្ញាតិឱ្យធ្វើអាជីវកម្ម នាវាគ្រប់ប្រភេទ ត្រូវមានសៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេស ដែលចេញដោយនាយកដ្ឋាននាវាជំនួញសមុទ្រ នៃក្រសួងសាធារណការ និងដឹកជញ្ជូន ឬ មន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត-ក្រុង ។

ម្ចាស់នាវាត្រូវដាក់ពាក្យសុំត្រួតពិនិត្យនាវារបស់ខ្លួន មកនាយកដ្ឋាននាវាជំនួញសមុទ្រ ឬមន្ទីរសាធារណការ និងដឹកជញ្ជូន ដើម្បីទទួលយកសៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេស ។ ពាក្យសុំត្រួតពិនិត្យនេះ ត្រូវមានបិទតែមត្រឹមត្រូវ និងត្រូវមានភ្ជាប់មកជាមួយ នូវប័ណ្ណសំគាល់នាវាមួយសន្លឹក ។

លក្ខន្តិកៈនៃសៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេស មានដូចតទៅ :

១-សៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេសមួយក្បាលប្រើប្រាស់បានសំរាប់តែនាវាមួយគ្រឿងប៉ុណ្ណោះ ។

២-លទ្ធផលនៃការត្រួតពិនិត្យលក្ខណៈបច្ចេកទេសរបស់នាវា ត្រូវកត់ចូលទៅក្នុងសៀវភៅនេះ ។

៣-ម្ចាស់នាវា ឬមេបញ្ជាការនាវា ឬអ្នកបើកបរ ត្រូវរក្សាទុកសៀវភៅនេះឱ្យបានល្អគង់វង់ សំរាប់បង្ហាញដល់ភ្នាក់ងារមានសមត្ថកិច្ចនៅរាល់ពេលត្រួតពិនិត្យ ។

៤-ក្រោយពីការត្រួតពិនិត្យនីមួយៗ មន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត-ក្រុងត្រូវផ្ញើមកនាយកដ្ឋាននាវាជំនួញសមុទ្រនៃក្រសួងសាធារណការ និង ដឹកជញ្ជូន នូវសេចក្តីចំលងអំពីការកត់សំគាល់ទាំងឡាយដែលទាក់ទងដល់សារក្រុង

ពិនិត្យលក្ខណៈបច្ចេកទេស និងការពិន័យបទល្មើស ចាប់តាំងពីការត្រួតពិនិត្យជាលើកដំបូងមក ។ ការកត់សំគាល់ទាំងនោះត្រូវតំកល់ទុកជាឯកសារសំរាប់នាវានីមួយៗ នៅនាយកដ្ឋាននាវាជំនួញសមុទ្រ ដើម្បីតាមដានជាប្រចាំ ។

៥-ការលើកលែងត្រួតពិនិត្យ ត្រូវបានអនុញ្ញាតចំពោះនាវាដែលត្រូវហាមឃាត់ធ្វើនាវាចរ ហើយឯកសារនាវាចរ (ប័ណ្ណសំគាល់នាវា និង លិខិតអនុញ្ញាតធ្វើអាជីវកម្ម) ត្រូវបានយកមកតំកល់ទុកនៅនាយកដ្ឋាននាវាជំនួញសមុទ្រ ឬមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង ។

៦-ក្នុងករណីដែលសៀវភៅនេះត្រូវបាត់ដោយប្រការណាមួយ ម្ចាស់នាវា ឬមេបញ្ជាការនាវា ឬ អ្នកបើកបរត្រូវរាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមូលដ្ឋាន រួចហើយត្រូវយកលិខិតបញ្ជាក់ការបាត់បង់នោះមកនាយកដ្ឋាននាវាជំនួញសមុទ្រ ឬ មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង ដើម្បីសុំធ្វើទុតិយតា ។

៧-ក្នុងករណីដែលសៀវភៅនេះសរសេរអស់ ឬទក់ ឬរលុបអក្សរមើលមិនច្បាស់ ត្រូវមកសុំសៀវភៅថ្មីនៅតាមស្ថាប័នផ្តល់ប័ណ្ណសំគាល់នាវា ។

## II. សៀវភៅម៉ាស៊ីននាវា

១-យន្តការី ត្រូវមានសៀវភៅម៉ាស៊ីននាវា សំរាប់តាមដានអំពីប្រវត្តិម៉ាស៊ីន និងការថែទាំ និងជួសជុលម៉ាស៊ីនដែលប្រើប្រាស់ក្នុងនាវា ។

២-យន្តការីត្រូវរក្សាទុកសៀវភៅម៉ាស៊ីននាវាឱ្យបានគង់វង់ កុំឱ្យរហែកបាត់សន្លឹកណាមួយឡើយ និងត្រូវបង្ហាញដល់ភ្នាក់ងារមានសមត្ថកិច្ចនៅរាល់ពេលត្រួតពិនិត្យ ។

៣-ក្នុងករណីសៀវភៅនេះត្រូវបាត់ យន្តការីត្រូវរាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមូលដ្ឋាន រួចយកលិខិតបញ្ជាក់ការបាត់បង់ដែលចេញដោយអាជ្ញាធរមូលដ្ឋាននោះមកនាយកដ្ឋាននាវាជំនួញសមុទ្រ ឬមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង ដើម្បីសុំសៀវភៅថ្មីមួយទៀត ។

៤-ក្នុងករណីសៀវភៅនេះ សរសេរអស់ ទក់ ឬរលុបអក្សរមើលមិនច្បាស់ ត្រូវមកសុំប្តូរយកសៀវភៅថ្មីនៅនាយកដ្ឋាននាវាជំនួញសមុទ្រ ឬមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង ។

## III. ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវា

### ១. លក្ខណៈបច្ចេកទេស

ក-សំបក : សំបកនាវា ទោះបីជាធ្វើពីឈើ ឬដែកក៏ដោយ ត្រូវមានគុណភាពធានាបាននូវសុវត្ថិភាពរបស់នាវា ទ្រព្យសម្បត្តិ ឬអាយុជីវិតមនុស្ស និងការការពារបរិស្ថាន ។

ខ-ប្រព័ន្ធម៉ាស៊ីន : ផ្នែកនីមួយៗនៃគ្រឿងម៉ាស៊ីន ត្រូវរៀបចំនៅក្នុងស្ថានភាពមួយ ដែលជៀសវាងបាននូវគ្រោះថ្នាក់អគ្គីភ័យ ឬ ការផ្ទុះគ្រឿងម៉ាស៊ីន ។ ម៉ាស៊ីនត្រូវដំណើរការល្អជានិរន្តន៍ មិនមានផ្នែកណាមួយខូចខាតមិនដំណើរការឡើយ ។ ត្រូវមានរបាំងព័ទ្ធជុំវិញម៉ាស៊ីនដើម្បីការពារកុំឱ្យអ្នកដំណើរ អ្នកមានភារកិច្ច ឬជនផ្សេងទៀតប៉ះនឹងម៉ាស៊ីន ឬប្រព័ន្ធម៉ាស៊ីន ដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់ ។

គ-ប្រព័ន្ធចង្កូត និង ហត្ថកិច្ច : ប្រព័ន្ធចង្កូត ត្រូវរៀបចំយ៉ាងណាឱ្យមានភាពរស់រវើក អាចបត់ងាកឆ្វេងស្តាំបានស្រួល ។ កន្លែងអង្គុយរបស់អ្នកបើកបរ ត្រូវមានភាពទូលាយមិនចើសចែង និង ត្រូវស្ថិតនៅក្នុងស្ថានភាពដែលអាចឱ្យអ្នកបើកបរមើលទៅមុខ សងខាង និងក្រោយបានច្បាស់លាស់ ។

ឃ- ដំបូល : ដំបូលត្រូវរៀបចំតាមរបៀបមួយ ដែលអាចកាត់បន្ថយសំពាធខ្យល់បក់ ឬរក្សាលំនឹងរបស់នាវា ។

- នាវាដែលមានបណ្តោយពី ២៥ម ឡើងទៅ អាចធ្វើដំបូលពេញដល់កន្សៀននាវាបាន ។

- នាវាដែលមានបណ្តោយ ២១ម ដល់ ២៤ម ការធ្វើដំបូលត្រូវទុកចំហ ៣ម ពីកន្សៀននាវា ។

- នាវាដែលមានបណ្តោយពី ១៨ម ដល់ ២០ម ការធ្វើដំបូលត្រូវទុកចំហពីពាក់កណ្តាលនាវារហូតដល់កន្សៀននាវា ។

ង- ស៊ីផ្លេ : នាវាសមុទ្រគ្រប់ប្រភេទ ត្រូវមានស៊ីផ្លេប្រើប្រាស់នៅពេលត្រូវការ ។

<u>ឧទាហរណ៍:</u> ពេលនាវាត្រៀមចូលចតផ្ទេរទំនិញ ឬអ្នកដំណើរ ពេលនាវាបំរុងចាកចេញពីកំពង់ផែ ឬកំពង់ចំណតពេលនាវាត្រូវការជៀងគ្នា ។

សំលេងស៊ីផ្លេនាវា ត្រូវឮស្លូវឱ្យបានចំងាយយ៉ាងតិចបំផុត ១៥០០ម ។

ច-ភ្លើងសញ្ញា

(១) - នាវាដឹកអ្នកដំណើរ អ្នកទេសចរ ទំនិញ ប្រេងឥន្ធនៈ និងនាវាសណ្តោងត្រូវមានភ្លើងសញ្ញា ដូចខាងក្រោម :

ភ្លើងបៃតងមួយនៅខាងស្តាំ និងភ្លើងក្រហមមួយនៅខាងឆ្វេង ដាក់អមសងខាងដំបូល ។ ភ្លើងពណ៌ទាំងពីរនេះត្រូវមើលឃើញពីចំងាយ ១០០០ម ក្នុងលក្ខណ្ឌអាកាសធាតុធម្មតា ។ ភ្លើងពណ៌ក្រហម និងបៃតង ត្រូវចាំង ១១២អង្សា ៣០ ទៅមុខ ។ ភ្លើងពណ៌ទាំងពីរនេះ ត្រូវមានដាក់ក្បាំង ដើម្បីកុំឱ្យមើលឃើញពីខាងក្រោយ ។

ភ្លើងពណ៌សមួយត្រូវដាក់នៅកន្សៀននាវា និងត្រូវចាំង ១៣៥អង្សា ទៅក្រោយ និងអាចមើលឃើញនៅចំងាយ ១៥០០ម ។

- ចំពោះនាវាដឹកអ្នកដំណើរ និងអ្នកទេសចរ ត្រូវមានភ្លើងពណ៌សដាក់នៅតាមដងក្តោង ដែលស្ថិតនៅចំពាក់កណ្តាលនាវា និងបណ្តោយអ័ក្សនាវា ហើយមានកំពស់ ៣ម ពីដំបូលឡើងទៅ ។ ភ្លើងពណ៌សនេះត្រូវមើលឃើញចំងាយ ១៥០០ម ក្នុងលក្ខខណ្ឌអាកាសធាតុធម្មតា និងត្រូវមានពន្លឺចាំង ២២៥ អង្សាទៅមុខ ។ ពេលថ្ងៃ ភ្លើងពណ៌សត្រូវជំនួសដោយពោងកងពណ៌ខ្មៅមួយ ដែលមានបន្ទាត់ផ្ចិត ០,៣ម ។

- ចំពោះនាវាដឹកទំនិញត្រូវមានភ្លើងពណ៌សមួយ និងភ្លើងពណ៌ក្រហមមួយថែមទៀត ។ ភ្លើងពណ៌សដាក់ពីលើភ្លើងពណ៌ក្រហមឃ្លាតពីគ្នាចំងាយ ០១ម ។ ពេលថ្ងៃភ្លើងពណ៌សនេះ ត្រូវជំនួសដោយត្រីកោណពណ៌ស ហើយភ្លើងពណ៌ក្រហម ត្រូវជំនួសដោយពោងកងពណ៌ខ្មៅ ។

- ចំពោះនាវាដឹកគ្រឿងផ្ទុះ ទំនិញប្រកបដោយគ្រោះថ្នាក់ និងគ្រឿងផ្ទុះត្រូវមានភ្លើងពណ៌មួយទៀត ដាក់ទន្ទឹមភ្លើងពណ៌សដែលបានកំណត់ខាងដើមរួចមក ។ នៅពេលថ្ងៃភ្លើងពណ៌ក្រហមនេះ ត្រូវជំនួសដោយអក្សរ B ពណ៌ក្រហម ។

-ចំពោះនាវាសណ្តោងដែលមានប្រវែងតិចជាង ១០០ម ត្រូវមានភ្លើងពណ៌ស ចំនួនពីរ ឃ្លាតពីគ្នាចំងាយ ០១ម ពីលើមកក្រោម ។ នៅពេលថ្ងៃភ្លើងពណ៌ស ត្រូវជំនួសដោយពោងកងពណ៌ខ្មៅ ។

២- ទូកសាឡាងដែលមានចំណុះលើសពី ២៥តោន ត្រូវមាន :

-ភ្លើងពីរជាប់នឹងដំបូល ។ ភ្លើងពណ៌ក្រហមនៅខាងឆ្វេង និងភ្លើងពណ៌បៃតងនៅខាងស្តាំ និងមានពន្លឺមើលឃើញក្នុងចំងាយ ៥០០ម និងត្រូវចាំង ១១២អង្សា ៣០ ទៅមុខ និងនៅចំហៀងសងខាង ។

-ភ្លើងពណ៌មួយនៅខាងកន្សៃចាំងពន្លឺ ៣៥អង្សា ទៅក្រោយ និងអាចមើលឃើញនៅចំងាយ ១៥០០ម ។

៣- ទូក សាឡាងដែលមានចំណុះស្មើ ឬតិចជាង ២៥តោនត្រូវមានភ្លើងពណ៌សភ្លឺគ្រប់ទិស កំពស់តិចបំផុត ២មពីដំបូលទូក ឬសាឡាង ។

ឆ-ឧបករណ៍សុវត្ថិភាព

*(១)-ពោងសង្គ្រោះ អាវសង្គ្រោះ*

នាវាសមុទ្រ ត្រូវមានពោង និងអាវសង្គ្រោះសំរាប់ការពារនៅពេលមានគ្រោះអាសន្ន។ ពោងសង្គ្រោះធំ ត្រូវមានចំនួនសមស្រប ទៅតាមចំនួនមនុស្សនៅលើនាវា ។ ពោងកងត្រូវមានចំនួនសមស្រប ដើម្បីប្រើប្រាស់ ជាជំនួយសង្គ្រោះ ។ បន្ថែមពីលើពោងសង្គ្រោះ នាវិក អ្នកដំណើរ ឬអ្នកទេសចរ ឬជនម្នាក់ៗនៅលើនាវា ត្រូវមានអាវសង្គ្រោះសំរាប់ត្រៀមបំរុងការពារនៅពេលមានគ្រោះអាសន្ន ។ ពោងសង្គ្រោះធំ ពោងកង និងអាវសង្គ្រោះ ត្រូវមានសរសេរឈ្មោះនាវា លេខនាវា និងឈ្មោះកំពង់ផែ ។ ពោងសង្គ្រោះធំ ពោងកង និងអាវសង្គ្រោះ ត្រូវរក្សាទុកឱ្យបានត្រឹមត្រូវ និងក្នុងល័ក្ខខ័ណ្ឌដែល គេអាចយកមកប្រើប្រាស់បានទាន់ពេលវេលា ។

*(២)-ស្ពានឆ្លង*

នាវាសមុទ្រត្រូវមានស្ពានឆ្លង ធ្វើអំពីឈើឬដែកស្រាល មាំស្អិត ដែលមានទទឹង ០.៥០មយ៉ាងតិច សំរាប់ឱ្យអ្នកដំណើរឆ្លងកាត់ដោយសុវត្ថិភាព ។ ស្ពានឆ្លងនេះ ត្រូវមានបង្កាន់ដៃសងខាង និងសំណាញ់ទ្រពីក្រោមផង ។

*(៣)-ឧបករណ៍ពន្លត់អគ្គីភ័យ*

នាវាសមុទ្រត្រូវមានឧបករណ៍ពន្លត់ភ្លើងគ្រប់ប្រភេទ សំរាប់ការពារពេលមានគ្រោះថ្នាក់ ។

*(៤)-ម៉ាស៊ីនបូមទឹក*

នាវាសមុទ្រត្រូវមានម៉ាស៊ីនបូមទឹក សំរាប់បូមទឹកចេញពេលមានទឹកចូល ។

*(៥)-កំណល់ការពារ*

នាវាសមុទ្រ ត្រូវមានកំណល់ការពារឈើ ឬកៅស៊ូកង់រថយន្ត ដាក់នៅសងខាងនាវា ដើម្បីការពារការប៉ះទង្គិចគ្នាដោយចៃដន្យ ។

*(៦)-ទ្វារសង្គ្រោះបន្ទាន់*

នាវាសមុទ្រត្រូវមានទ្វារសង្គ្រោះគ្រប់គ្រាន់សំរាប់ធានាដល់អាយុជីវិតមនុស្សនៅពេលមានគ្រោះអាសន្ន ។

*(៧)-សញ្ញាប្រកាសគ្រោះអាសន្ន*

នាវាសមុទ្រ ពិសេសនាវាដឹកជញ្ជូនអ្នកដំណើរ និងនាវាទេសចរណ៍ត្រូវមានសញ្ញាសំលេងសំរាប់ប្រកាសគ្រោះអាសន្នផ្សេងៗដែលអាចកើតមានចំពោះនាវា ។

*(៨)-យុថ្កា*

នាវាសមុទ្រគ្រប់ប្រភេទ ត្រូវមានយុថ្កាដោយភ្ជាប់ខ្សែពួរមាំជាប់ល្អការពារមិនឱ្យដាច់ ឬរសាត់នាវាបាន ។ លើសពីនេះ នាវាត្រូវមានខ្សែពួរសំរាប់ចងទប់ពេលនាវាចូលចតនៅកំពង់ផែ ។

*(៩)-ថ្នាំពេទ្យបំរុង និងបង្គន់អនាម័យ*

នាវាដឹកអ្នកដំណើរ និងអ្នកទេសចរ ត្រូវមានប្រអប់ថ្នាំពេទ្យ និងមានថ្នាំពេទ្យបំរុងមួយចំនួន សំរាប់ការពារនៅពេលមានការឈឺថ្កាត់ដោយចែដន្យ ។ ប្រភេទថ្នាំប្រើប្រាស់ត្រូវមានកំរិតស្រាលមិនបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាព តែអាចជួយបន្ថយការឈឺថ្កាត់បានមុនពេលនាវាចូលដល់កំពង់ផែ ។

នាវាដឹកអ្នកដំណើរ និងអ្នកទេសចរត្រូវមានបង្គន់អនាម័យល្អជានិច្ច ។

*(១០)-វិទ្យុទាក់ទង*

នាវាសមុទ្រគ្រប់ប្រភេទត្រូវមានវិទ្យុទាក់ទង ដែលអាចបញ្ជូនពត៌មានមកសមត្ថកិច្ចបាននៅពេលមានគ្រោះថ្នាក់ធម្មជាតិ ឬ ចោរសមុទ្រ ឬករណីប្រធានស័ក្តនានា ដើម្បីសុំជំនួយសង្គ្រោះ ។

*(១១)-ឧបករណ៍ស្ទង់ទឹក*

នាវាសមុទ្រគ្រប់ប្រភេទ ត្រូវមានឧបករណ៍ស្ទង់ទឹក ដើម្បីការពារនាវាកុំឱ្យតឿង ។

ជ-ធុងសំរាម

នាវាសមុទ្រគ្រប់ប្រភេទ ត្រូវមានធុងសំរាម ដើម្បីរក្សាទុកសំរាម ពិសេសជាតិផ្លាស្ទិច ឬសំណល់ដែលមិនអាចរលាយក្នុងទឹកបាន យកមកបោះបង់ចោលនៅទីកន្លែងកំណត់ដាក់សំរាម ។

ឈ-គំនូសក្រិត

នាវាសមុទ្រគ្រប់ប្រភេទ ត្រូវមានគំនូសក្រិតបញ្ជាក់ពីទំងន់ផ្ទុកអតិបរមា និងទំងន់នាវាពេលពុំទាន់ផ្ទុក។ គំនូសក្រិតត្រូវមានពណ៌ស សងខាងនាវានៅផ្នែកខាងមុខ ផ្នែកខាងក្រោយ និងនៅផ្នែកកណ្តាលនាវា ។ គំនូសក្រិតត្រូវមានបណ្តោយ ០.៥០ម និងទទឹង ៥ស.ម ។ គំនូសក្រិតទំងន់ផ្ទុកអតិបរមា និងគំនូសក្រិតពេលនាវាមិនទាន់ផ្ទុកស្ថិតនៅលើអ័ក្សតែមួយចំពោះនៅផ្នែកកណ្តាលនាវា ។

ញ-ពណ៌របស់នាវា

ពណ៌របស់នាវាសមុទ្រគ្រប់ប្រភេទ អាស្រ័យទៅតាមម្ចាស់នាវាជាអ្នកកំណត់ ។ ការប្តូរពណ៌នាវា ត្រូវមានលិខិតអនុញ្ញាតពីនាយកដ្ឋាននាវាជំនួញសមុទ្រ ឬមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង ។

**២-ប្រភេទនៃការត្រួតពិនិត្យលក្ខណៈបច្ចេកទេស**

ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវាមានបីប្រភេទ :

ក- ការត្រួតពិនិត្យជាកាតព្វកិច្ច គឺជាការត្រួតពិនិត្យនៅគ្រាដំបូងមុនពេលដាក់ពាក្យសុំអនុញ្ញាតបើកបរធ្វើអាជីវកម្មដឹកជញ្ជូន ។

ខ- ការត្រួតពិនិត្យតាមពេលកំណត់ អនុវត្តចំពោះនាវាដែលបាន ឬកំពុងធ្វើអាជីវកម្ម និងត្រូវធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេស តាមពេលវេលាដែលនាយកដ្ឋាននាវាជំនួញសមុទ្រ ឬមន្ទីរសាធារណការ និងដឹកជញ្ជូន បានកំណត់ ។

ការត្រួតពិនិត្យនេះ ត្រូវធ្វើរយៈពេល ៦ខែម្តងចំពោះនាវាសំបកឈើ និង ០១ ឆ្នាំម្តងចំពោះនាវាសំបកដែក ។ ក្នុងករណីពិសេស រយៈពេលនេះត្រូវបានបង្រួញខ្លីជាងនេះទៅទៀត តាមការវាយតំលៃរបស់សមត្ថកិច្ចត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវា ។

គ-ការត្រួតពិនិត្យឆ្លក់ គឺជាការត្រួតពិនិត្យមិនឱ្យសាមីខ្លួនដឹងជាមុន ។ ការត្រួតពិនិត្យនេះមានទិសដៅធានាដល់ការគោរពច្បាប់ លិខិតអនុញ្ញាតិធ្វើអាជីវកម្ម និងលិខិតបទដ្ឋានផ្សេងៗដែលអ្នកប្រើប្រាស់នាវាត្រូវមានគ្រប់គ្រាន់តាមការកំណត់របស់រដ្ឋ ។

ការពិនិត្យឆ្លក់ អាចធ្វើបានគ្រប់ពេលវេលា និងគ្រប់ទីកន្លែងតាមផ្លូវសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ។

**៣-សិទ្ធិអំណាចក្នុងការត្រួតពិនិត្យលក្ខណៈបច្ចេកទេស**

ក-ការត្រួតពិនិត្យជាកាតព្វកិច្ច និងការត្រួតពិនិត្យតាមពេលកំណត់

-នៅក្រសួងសាធារណការ និងដឹកជញ្ជូន ការត្រួតពិនិត្យនេះ ត្រូវធ្វើឡើងដោយនាយកដ្ឋាននាវាជំនួញសមុទ្រ ។

-នៅមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង ការត្រួតពិនិត្យនេះ ត្រូវធ្វើឡើងដោយការិយាល័យដឹកជញ្ជូន ។

ខ-ការពិនិត្យឆ្លក់

នៅថ្នាក់ក្រសួង ការពិនិត្យឆ្លក់ ត្រូវធ្វើឡើងដោយសមត្ថកិច្ចត្រួតពិនិត្យឆ្លក់ ក្នុងនោះតំណាងក្រសួងសាធារណការ និងដឹកជញ្ជូនជាប្រធាន ។ ការពិនិត្យនេះធ្វើឡើងតាមការកោះអញ្ជើញរបស់ប្រធាន នៅពេលដែលក្រសួងសាធារណការ និងដឹកជញ្ជូនយល់ថាជាការចាំបាច់ ។

នៅតាមខេត្ត-ក្រុងនានា ការពិនិត្យឆ្លក់ត្រូវធ្វើឡើងដោយសមត្ថកិច្ចត្រួតពិនិត្យឆ្លក់ ដែលតែងតាំងដោយអាជ្ញាធរដែនដីខេត្ត-ក្រុង ក្នុងនោះតំណាងមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុងជាប្រធាន ។ ការពិនិត្យឆ្លក់នេះធ្វើឡើងតែនៅក្នុងក្របខ័ណ្ឌខេត្ត-ក្រុងរបស់ខ្លួន តាមការកោះអញ្ជើញរបស់ប្រធាននៅពេលណាដែលមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុងយល់ថាជាការចាំបាច់ ។

គ-កំណត់ហេតុត្រួតពិនិត្យ

នៅពេលត្រួតពិនិត្យ សមត្ថកិច្ចត្រូវតែធ្វើកំណត់ហេតុត្រួតពិនិត្យ និងកត់ត្រាចំណុចខ្វះខាតចូលក្នុងសៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវា ។

ក្នុងករណីដែលនាវាមានចំណុចខ្វះខាត ពុំធានាសុវត្ថិភាពគ្រប់គ្រាន់ សមត្ថកិច្ចត្រូវតែបង្ខំឱ្យផ្អាកសកម្មភាពនាវាភ្លាម ជាបន្ទាន់ ។ សមត្ថកិច្ចត្រួតពិនិត្យត្រូវដកហូតយកប័ណ្ណសំគាល់នាវា និងលិខិតអនុញ្ញាត្តិធ្វើអាជីវកម្មយកទៅ[illegible]ខេត្តនោ

នាយកដ្ឋាននាវាជំនួញសមុទ្រ ឬមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង ដោយចេញបង្កាន់ដៃបញ្ជាក់អំពីការដកហូតនេះឱ្យទៅម្ចាស់នាវា ។

ឯកសារនាវាចរទាំងនេះ នឹងត្រូវបានប្រគល់ឱ្យម្ចាស់នាវាវិញ ដើម្បីដំណើរការអាជីវកម្មរបស់ខ្លួនក្នុងករណីដែលនាវាត្រូវបានបំពេញសព្វគ្រប់រាល់ចំណុចខ្វះខាតខាងលើ ។

ឃ-កាលបរិច្ឆេទកំណត់ក្នុងការត្រួតពិនិត្យ

-ម្ចាស់នាវាត្រូវយកនាវារបស់ខ្លួន មកដាក់ឱ្យធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេស ដែលនាយកដ្ឋាននាវាជំនួញសមុទ្រនៃក្រសួងសាធារណការ និងដឹកជញ្ជូន ឬមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុងបានកំណត់ ។

-ក្នុងករណីពុំបានគោរពតាមកាលបរិច្ឆេទកំណត់នោះទេ នាវាត្រូវតែទទួលការផាកពិន័យគិតជាទឹកប្រាក់ចំនួន ៥០០០ រៀល ក្នុងមួយថ្ងៃ គិតចាប់ពីថ្ងៃផុតកំណត់ ។

## ជំពូក IV

## សៀវភៅវិជ្ជាជីវៈនាវិក វិញ្ញាបនបត្រ និង សៀវភៅនិជ្ជាការធ្វើដំណើរ

### I . សៀវភៅវិជ្ជាជីវៈនាវិក

១-នាវិកគ្រប់ជាន់ថ្នាក់ រួមមាន មេបញ្ជាការនាវា មេបញ្ជាការរងនាវា និងយន្តការី ព្រមទាំងកម្មករនាវាដែលបំពេញភារកិច្ចបំរើឱ្យសេវាកម្មនាវាចរណ៍ ក្នុងដែនសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ឬអន្តរជាតិ ត្រូវមានសៀវភៅវិជ្ជាជីវៈនាវិកសំរាប់បង្ហាញដល់សមត្ថកិច្ចត្រួតពិនិត្យ ។

២-សៀវភៅវិជ្ជាជីវៈនាវិក ត្រូវចេញដោយនាយកដ្ឋាននាវាជំនួញសមុទ្រនៃក្រសួងសាធារណការ និង ដឹកជញ្ជូនឱ្យនាវិកប្រើប្រាស់រយៈពេល ៣ឆ្នាំ ។ សៀវភៅនេះ អាចពន្យារពេលប្រើប្រាស់ ២លើក ដែលក្នុងមួយលើកមានរយៈពេល ២ឆ្នាំ ។

៣-ម្ចាស់នាវាត្រូវធានាថា នាវិកទាំងអស់ដូចមានចែងនៅក្នុងចំណុច I-១ ខាងលើនេះ មានសៀវភៅវិជ្ជាជីវៈនាវិកមុននឹងអនុញ្ញាតឱ្យនាវិកទាំងនោះបំរើការងារនៅក្នុងនាវារបស់ខ្លួនបាន ។

៤-នាវិកត្រូវដាក់ពាក្យមកនាយកដ្ឋាននាវាជំនួញសមុទ្រ ដើម្បីសុំសៀវភៅវិជ្ជាជីវៈនាវិកតាមសំណុំលិខិត ដូចខាងក្រោម :

ក-ពាក្យសុំសៀវភៅវិជ្ជាជីវៈនាវិក ០១សន្លឹក ដែលមានបិទតែមត្រឹមត្រូវ ។

ខ-លិខិតបញ្ជាក់ទីលំនៅមួយច្បាប់ និងប័ណ្ណគ្រួសារ ឬអត្តសញ្ញាណប័ណ្ណ ឬប័ណ្ណសំគាល់ខ្លួន ។

គ-ប្រវត្តិរូបសង្ខេបមួយច្បាប់ដោយមានបញ្ជាក់អំពីកិរិតវប្បធម៌ និងបទពិសោធន៍ការងារនាវាចរ និងដោយមានភ្ជាប់មកជាមួយនូវរូបថត ៤ x ៦ ចំនួនបីសន្លឹក ។

ឃ-លិខិតពិនិត្យសុខភាពបច្ចុប្បន្ន ០១ច្បាប់ ។

៦-នាវិក ត្រូវរក្សាសៀវភៅវិជ្ជាជីវៈនាវិករបស់ខ្លួនឱ្យបានគង់វង្ស មិនមានរហែក ឬបាត់បង់សន្លឹកណាមួយឡើយ ។ ក្នុងករណីបាត់បង់ ទក់ ឬរលុបតួអក្សរណាមួយ នាវិកត្រូវស្នើសុំប្តូរយកសៀវភៅវិជ្ជាជីវៈនាវិកថ្មីពីនាយកដ្ឋាននាវាជំនួញសមុទ្រ នៃក្រសួងសាធារណការ និងដឹកជញ្ជូន ។

## II . វិញ្ញាបនប័ត្របញ្ជាក់សមត្ថភាពជំនាញ

វិញ្ញាបនប័ត្របញ្ជាក់សមត្ថភាពជំនាញ ត្រូវអនុញ្ញាតផ្តល់ជូនអោយនាវិក តាមសមត្ថភាពសមស្រប ដោយក្រសួងសាធារណការ និងដឹកជញ្ជូន ( នាយកដ្ឋាននាវាជំនួញសមុទ្រ ) ។

នាវាសមុទ្រគ្រប់ប្រភេទដែលមានទំងន់ផ្ទុកចាប់ពី ២០តោនឡើងទៅ ត្រូវមានមេបញ្ជាការរង ឬមានកំលាំងម៉ាស៊ីនចាប់ពី ៣០ សេះត្រូវមាន យន្តការី ។

### ១. វិញ្ញាបនប័ត្រមេបញ្ជាការរង

ក-វិញ្ញាបនប័ត្រមេបញ្ជាការរងថ្នាក់លេខ១ : អ្នកមានវិញ្ញាបនប័ត្រមេបញ្ជាការរងថ្នាក់លេខ១ អាចបើកបរនាវាដែលមានទំងន់ផ្ទុកចាប់ពី ៣០១តោន ឬនាវាសណ្តោងដែលមានសមត្ថភាពអូសចាប់ពី ៣០១តោន ឡើងទៅ និងត្រូវមានអាយុយ៉ាងតិច ២៥ឆ្នាំ ។

ខ-វិញ្ញាបនប័ត្រមេបញ្ជាការរងថ្នាក់លេខ២ : អ្នកមានវិញ្ញាបនប័ត្រមេបញ្ជាការរងថ្នាក់លេខ២ អាចបើកបរនាវាដែលមានទំងន់ផ្ទុកចាប់ពី ៥១តោន ដល់ ៣០០តោន ឬនាវាសណ្តោងដែលមានសមត្ថភាពអូសចាប់ពី ៥១តោន ដល់ ៣០០តោន និងត្រូវមានអាយុយ៉ាងតិច ២៥ឆ្នាំ ។

គ-វិញ្ញាបនប័ត្រមេបញ្ជាការរងថ្នាក់លេខ៣ : អ្នកមានវិញ្ញាបនប័ត្រមេបញ្ជាការរងថ្នាក់លេខ៣ អាចបើកបរនាវាដែលមានទំងន់ផ្ទុកចាប់ពី ៥០តោនចុះក្រោម និងត្រូវមានអាយុយ៉ាងតិច ២២ឆ្នាំ ។

### ២. វិញ្ញាបនប័ត្រយន្តការី

នាវាសមុទ្រគ្រប់ប្រភេទ ត្រូវមានយន្តការី ដែលមានភារកិច្ចទទួលខុសត្រូវលើផ្នែកម៉ាស៊ីន ។ យន្តការីម្នាក់ៗត្រូវមានវិញ្ញាបនប័ត្រយន្តការីជាប់នឹងខ្លួន ។

ក-វិញ្ញាបនប័ត្រយន្តការីថ្នាក់លេខ១ : អ្នកមានវិញ្ញាបនប័ត្រយន្តការីថ្នាក់លេខ១ ត្រូវនៅប្រចាំការនៅលើនាវាដែលមានកំលាំងម៉ាស៊ីនពី ១៥១សេះឡើងទៅ និងត្រូវមានអាយុយ៉ាងតិច ២២ឆ្នាំ ។

ខ-វិញ្ញាបនប័ត្រយន្តការីថ្នាក់លេខ២ : អ្នកមានវិញ្ញាបនប័ត្រយន្តការីថ្នាក់លេខ២ ត្រូវនៅប្រចាំការនៅលើនាវាដែលមានកំលាំងម៉ាស៊ីនពី ៨១សេះដល់ ១៥០សេះ និងត្រូវមានអាយុយ៉ាងតិច ២២ឆ្នាំ ។

គ-វិញ្ញាបនប័ត្រយន្តការីថ្នាក់លេខ៣ : អ្នកមានវិញ្ញាបនប័ត្រយន្តការីថ្នាក់លេខ៣ ត្រូវនៅប្រចាំការនៅលើនាវាដែលមានកំលាំងម៉ាស៊ីនពី ៣០សេះ ដល់ ៨០សេះ និងត្រូវមានអាយុយ៉ាងតិច ២០ឆ្នាំ ។

## III . វិញ្ញាបនប័ត្រមេបញ្ជាការនាវា

នាវាសមុទ្រគ្រប់ប្រភេទដែលមានកំលាំងម៉ាស៊ីនចាប់ពី ៣០សេះឡើងទៅ ត្រូវមានមេបញ្ជាការនាវា ។

វិញ្ញាបនប័ត្រមេបញ្ជាការនាវា ត្រូវផ្តល់ជូនដោយក្រសួងសាធារណការ និងដឹកជញ្ជូន (នាយកដ្ឋាននាវាជំនួញសមុទ្រ) អោយនាវិកដែលបានបំពេញតាមលក្ខ័ណ្ឌដូចខាងក្រោម :

១-ប្រើប្រាស់រយៈពេល ៣ឆ្នាំ ចំពោះនាវិកដែលបានបំពីការងារជាក់ស្តែងលើនាវាយ៉ាងតិចបំផុតរយៈពេល ៥ឆ្នាំ ដោយមានលិខិតបញ្ជាក់សមត្ថភាពពីមេបញ្ជាការនាវា ដែលគ្រប់គ្រងនាវិកនោះ ។

២-ប្រើប្រាស់រយៈពេល ៥ឆ្នាំ ចំពោះនាវិកដែលបានឆ្លងកាត់វគ្គសិក្សាថ្នាក់មេបញ្ជាការនាវា ដោយមានភ្ជាប់សញ្ញាប័ត្រមកជាមួយផង ។

៣-មានសុខភាពល្អ និង អាយុយ៉ាងតិច ២៥ឆ្នាំ ។

## IV. សៀវភៅទិដ្ឋាការធ្វើដំណើរ

១-នាវាសមុទ្រគ្រប់ប្រភេទ ត្រូវមានសៀវភៅទិដ្ឋាការធ្វើដំណើរ ។ សៀវភៅនេះ ត្រូវចេញដោយ នាយកដ្ឋាននាវាជំនួញសមុទ្រ ឬ មន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត-ក្រុង នៅពេលបានទទួលលិខិតអនុញ្ញាតិប្រកបអាជីវកម្មដឹកជញ្ជូន ឬ លិខិតអនុញ្ញាតិប្រកបអាជីវកម្មធ្វើនេសាទហើយ ។

២-សៀវភៅទិដ្ឋាការធ្វើដំណើរ ត្រូវប្រើប្រាស់សំរាប់បង្ហាញដល់ភ្នាក់ងារមានសមត្ថកិច្ច នៅរាល់ប៉ុស្តិ៍ត្រួតពិនិត្យនាវាចរផ្លូវសមុទ្រ ។

៣-ក្នុងករណីដែលសៀវភៅនេះ ត្រូវបាត់ដោយប្រការណាមួយ មេបញ្ជាការនាវា ត្រូវរាយការណ៍ជាបន្ទាន់ដល់អាជ្ញាធរមូលដ្ឋាន រួចហើយយកលិខិតបញ្ជាក់ការបាត់បង់ ដែលចេញដោយអាជ្ញាធរមូលដ្ឋាននោះមកនាយកដ្ឋាននាវាជំនួញសមុទ្រ ឬ មន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត-ក្រុង ដើម្បីប្តូរយកសៀវភៅថ្មីមួយទៀត ។

៤-ក្នុងករណីដែលសៀវភៅនេះ សរសេរអស់ ទក់ ឬលុបអក្សរមើលមិនឃើញច្បាស់ ត្រូវយកសៀវភៅនេះមកប្តូរយកសៀវភៅថ្មីមួយទៀត នៅនាយកដ្ឋាននាវាជំនួញសមុទ្រ ឬ មន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត-ក្រុង ។

# ជំពូក V

# ការធ្វើអាជីវកម្ម

## I. ការផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្ម

មុនធ្វើអាជីវកម្ម នាវាសមុទ្រគ្រប់ប្រភេទដូចមានចែងនៅក្នុងជំពូក I ត្រង់ចំណុច I ត្រូវមានលិខិតអនុញ្ញាតិធ្វើអាជីវកម្មដែលផ្តល់ដោយស្ថាប័ន ដូចមានចែងនៅត្រង់ចំណុច I-១ និង I-២ នៃជំពូកនេះ ។

អាជីវករ ឬ ម្ចាស់នាវា ឬក្រុមហ៊ុននាវាដែលមានមូលដ្ឋាននៅប្រទេសកម្ពុជា ប្រកបអាជីវកម្មនាវាចរក្រៅប្រទេស ឬឆ្លងដែន ត្រូវមានលិខិតអនុញ្ញាតិធ្វើអាជីវកម្មដែលផ្តល់ដោយនាយកដ្ឋាននាវាជំនួញសមុទ្រ នៃក្រសួងសាធារណការ និងដឹកជញ្ជូន ។

លិខិតអនុញ្ញាតិធ្វើអាជីវកម្ម ប្រើប្រាស់បានរយៈពេលកំណត់ ០១ឆ្នាំ និងសំរាប់តែគោលដៅមួយជាកំណត់ទោះជានៅក្នុងខេត្ត-ក្រុង តែមួយក៏ដោយ ។

## II .ការដាក់ពាក្យសុំលិខិតអនុញ្ញាតិធ្វើអាជីវកម្ម

ម្ចាស់នាវាត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាត្តិធ្វើអាជីវកម្មនៅតាមស្ថាប័ន ដូចមានចែងនៅក្នុងជំពូក I ត្រង់ចំណុច I-១ និង I-២ ខាងលើ តាមសំណុំលិខិតដូចខាងក្រោម :

១-ពាក្យសុំ ០១ច្បាប់ ដែលមានបិទតែមត្រឹមត្រូវ

២-ប័ណ្ណសំគាល់នាវា

៣-សៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេស ។

អាជីវករ ឬម្ចាស់នាវា ឬ ក្រុមហ៊ុននាវាត្រូវបំពេញបែបបទថ្មីដើម្បីប្រកបអាជីវកម្ម ក្នុងករណី :

១-ប្តូរគោលដៅ

២-ប្តូរកម្មវត្ថុធ្វើអាជីវកម្ម ។

នាវា ដែលប្រកបអាជីវកម្មក្រៅប្រទេស ឬឆ្លងដែនជាទៀងទាត់ របស់អាជីវករ ឬម្ចាស់នាវា ឬក្រុមហ៊ុននាវា ដែលមានមូលដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា ត្រូវគោរពតាមលក្ខ័ណ្ឌដូចខាងក្រោម :

១-ពាក្យសុំលិខិតអនុញ្ញាត្តិធ្វើអាជីវកម្ម ដែលមានបិទតែមត្រឹមត្រូវ

២-វិញ្ញាបនប័ត្រចុះបញ្ជីនាវា

៣-លិខិតអនុញ្ញាត្តិចុះបញ្ជីក្រុមហ៊ុនពីក្រសួងពាណិជ្ជកម្ម

៤-លិខិតធានារ៉ាប់រង

៥-វិញ្ញាបនប័ត្រផ្សេង១ស្របទៅតាមអនុសញ្ញាអន្តរជាតិ

៦-បង្កាន់ដៃពន្ធដារ ។

## ជំពូក VI

## ការផ្ទេរកម្មសិទ្ធិនាវា កាត់ឈ្មោះ

រាល់ការប្តូរនាវាគ្រប់ប្រភេទ ម្ចាស់នាវា ត្រូវមានការផ្ទេរកម្មសិទ្ធិ ឬកាត់ឈ្មោះដើម្បីឱ្យពេញលក្ខណៈច្បាប់ ។ នាវាណាដែលបានប្តូរម្ចាស់គ្រប់គ្រងហើយ ហើយពុំបានធ្វើការផ្ទេរមកម្ចាស់ថ្មី ការទទួលខុសត្រូវចំពោះមុខច្បាប់លើនាវានោះ ត្រូវស្ថិតនៅលើម្ចាស់ដើមដដែល ។

### I- នីតិវិធីធ្វើការផ្ទេរ

ម្ចាស់នាវាថ្មី ត្រូវធ្វើការផ្ទេរកម្មសិទ្ធិនាវានៅតាមស្ថាប័នដូចមានចែងក្នុងចំណុច I-១ និង I-២ នៃជំពូក I ខាងលើ ។

ក្រោយពីធ្វើការផ្ទេរកម្មសិទ្ធិរួច មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង ត្រូវធ្វើរបាយការណ៍ ជូនអគ្គនាយកដ្ឋាននាវាជំនួញសមុទ្រ នៃក្រសួងសាធារណការ និង ដឹកជញ្ជូនក្នុងរយៈពេលយ៉ាងយូរបំផុត ៧ថ្ងៃ ។

## II- សំណុំលិខិតផ្ទេរកម្មសិទ្ធិ

ពាក្យសុំផ្ទេរកម្មសិទ្ធិ ត្រូវមានសំណុំលិខិតដូចខាងក្រោម :

១-ពាក្យសុំផ្ទេរកម្មសិទ្ធិ ០១សន្លឹក ដែលមានបិទតែមត្រឹមត្រូវ

២-ប័ណ្ណសំគាល់នាវា

៣-លិខិតលក់ដែលមានចុះហត្ថលេខាអ្នកលក់ ០១សន្លឹក និងអ្នកទិញ ០១សន្លឹក

៤-លិខិតបញ្ជាក់ទីលំនៅរបស់អ្នកលក់ ០១សន្លឹក និងអ្នកទិញ ០១សន្លឹក ដោយមានភ្ជាប់ប័ណ្ណគ្រួសារ ឬ អត្តសញ្ញាណប័ណ្ណ ឬលិខិតសំគាល់ខ្លួន ។

## III- រយៈពេលផ្ទេរកម្មសិទ្ធិ

ការផ្ទេរកម្មសិទ្ធិត្រូវបំពេញឱ្យហើយស្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ១៥ ថ្ងៃ គិតចាប់ពីថ្ងៃដែលធ្វើលិខិតលក់រួច ។

នាយកខុទ្ទការល័យ អគ្គនាយកដឹកជញ្ជូន អគ្គនាយករដ្ឋបាល អគ្គាធិការ មន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត-ក្រុង ត្រូវធ្វើការផ្សព្វផ្សាយជាបន្ទាន់ ដើម្បីអោយសាធារណៈជន និង ស្ថាប័ននានាបានជ្រួតជ្រាប និង អនុវត្តតាមសារាចរនេះ អោយមានប្រសិទ្ធភាពខ្ពស់ ។

ភ្នំពេញ ថ្ងៃទី ០៧ ខែ ៦ ឆ្នាំ ១៩៩៩

រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន MS SH

ឃិ តាំងលីម

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងទេសចរណ៍
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- សាលាខេត្ត-ក្រុង តាមឆ្នេរសមុទ្រ
  "ដើម្បីជូនជ្រាប"
- គ្រប់អង្គភាពក្រោមឱវាទក្រសួង
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ